ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

លេខ : ៣៣០៤/២៥ មស.ន.នក

**សូមគោរពជូន**

**ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កម្មវត្ថុ** : សំណើសុំហត្ថលេខាលើសេចក្តីព្រាងប្រកាសអន្តរក្រសួង និងនិយាមនីតិវិធីប្រតិបត្តិ ស្តីពីគោលការណ៍ និងនីតិវិធី នៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយករងនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ។

**យោង** : - ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៤៣ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា

- អនុក្រឹត្យលេខ ៣០៩ អនក្រ.បក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ស្តីពីតួនាទីនិងភារកិច្ចរបស់ក្រសួងមុខងារសាធារណៈ ក្នុងក្របខណ្ឌជាលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ក្រសួងមុខងារសាធារណៈ បានរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួង និងនិយាមនីតិវិធីប្រតិបត្តិ ស្តីពីគោលការណ៍ និងនីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយករង នៃ គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈដោយមានគោលបំណងដើម្បីលើកកម្ពស់ ប្រសិទ្ធភាពនៃការដឹកនាំ និងគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយករង នៃគ្រឹះស្ថានសិក្សា ដូចមានគោរពជូនភ្ជាប់។

សេចក្តីព្រាងប្រកាសអន្តរក្រសួង និងនិយាមនីតិវិធីប្រតិបត្តិនេះ បានដាក់ឆ្លងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់រួចរាល់ហើយ កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៥។ អនុលោមតាមនីតិវិធីជាធរមាន ការរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួង និងនិយាមនីតិវិធីប្រតិបត្តិនេះ តម្រូវឱ្យមានហត្ថលេខារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ មុននឹងដាក់ឱ្យប្រើប្រាស់ជាផ្លូវការ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចចុះហត្ថលេខាលើសេចក្តីព្រាងប្រកាសអន្តរក្រសួងខាងលើ តាមការគួរ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅពីខ្ញុំ។

ថ្ងៃ អង្គារ ៦ កើត ខែ អាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ហ៊ុន_ម៉ានី**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ** **ក្រសួងមហាផ្ទៃ** **ក្រសួងអប់រំ យុវជន និងកីឡា**

លេខ : ៣៣០៦/២៥មស.ន.នក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## គោលការណ៍ និងនីតិវិធី នៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយករង នៃគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ ០៦.នស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ



ផ្លូវវត្តអង្គតាមិញ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កម្ពុជា
St. Watangtaminh, Sangkat Chomchoa, Khan Posenchey,
Phnom Penh, CAMBODIA
ទូរស័ព្ទ : (+៨៥៥) ២៣ ៨៦៦ ៥០១
Phone : (+855) 23 866 501
www.mcs.gov.kh

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២២៤/១៥៥៩ ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលព្រះរាជក្រឹត្យស្ដីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០១/៣៤១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៣១៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ នៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- បានឃើញអនុក្រឹត្យលេខ២១៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២៥ ស្ដីពីគោលការណ៍និងនីតិវិធីនៃការតែងតាំង ការផ្លាស់ប្ដូរ និងការបញ្ចប់មុខតំណែងនាយក នៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ
- យោងតាមសំណូមពរចាំបាច់នៃការងារ។

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ..**

ប្រកាសនេះ កំណត់អំពីគោលការណ៍និងនីតិវិធីនៃការតែងតាំង ការផ្លាស់ប្ដូរ និងការបញ្ចប់មុខតំណែងនាយករងនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព នៃការដឹកនាំ គ្រប់គ្រងគ្រឹះស្ថាន និងការផ្ដល់សេវាអប់រំ។

**ប្រការ២ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ត្រីដែលពាក់ព័ន្ធនឹងការជ្រើសរើស ការវាយតម្លៃ ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយករង នៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ។

## ជំពូកទី២
## គោលការណ៍និងនីតិវិធី

**ប្រការ៣ .-**

ការតែងតាំងមុខតំណែងនាយករងនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវផ្អែកលើមុខតំណែងទំនេរ លក្ខខណ្ឌចាំបាច់ និងលក្ខខណ្ឌទូទៅសម្រាប់មុខតំណែង ដើម្បីធានាបាននូវនិរន្តរភាព និងប្រសិទ្ធភាពការងារក្នុងគ្រឹះស្ថាន។

ការតែងតាំងមុខតំណែងនាយករងនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈក្នុងចំនួនណាមួយ ត្រូវអនុវត្តដោយអនុលោមតាមនិយាមរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានជាធរមាន។

**ប្រការ៤ .-**

ការតែងតាំងនាយករងនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ សម្រាប់ជំនួសនាយករងដែលត្រូវចូលនិវត្តន៍ ត្រូវរៀបចំតែងតាំងឱ្យបានរួចរាល់ក្នុងរយៈពេលយ៉ាងតិច ៣(បី)ខែ មុនដល់កាលកំណត់ចូលនិវត្តន៍។ ចំពោះមុខតំណែងនាយករងនៅទំនេរដោយមូលហេតុផ្សេងៗ ត្រូវរៀបចំតែងតាំងឱ្យបានរួចរាល់យ៉ាងយូរក្នុងរយៈពេល ៣(បី)ខែ។

ក្នុងករណីគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ដែលមានមុខតំណែងនាយករងដែលត្រូវចូលនិវត្តន៍ ឬនាយករងនៅទំនេរដោយមូលហេតុផ្សេងៗ នាយកត្រូវបង្កើតគណៈកម្មការវាយតម្លៃ ដើម្បីជ្រើសរើសបេក្ខភាពនាយករងថ្មី និងត្រូវលើកសំណើសុំតែងតាំង ទៅអភិបាលក្រុង ស្រុក ខណ្ឌ តាមរយៈប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ។

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកិច្ចប្រជុំគណៈអភិបាលរបស់ខ្លួន ដោយត្រូវមានការចូលរួមពីប្រធានគណៈកម្មការវាយតម្លៃ ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ប្រធានការិយាល័យគ្រប់គ្រងធនធានមនុស្ស/ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក ដើម្បីពិនិត្យ ពិភាក្សា និងសម្រេចលើសំណើតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងនាយករង ដោយដីការបស់អភិបាលក្រុង ស្រុក។ ដោយឡែករាជធានីភ្នំពេញ បន្ទាប់ពីទទួលបានសំណើពីអភិបាលខណ្ឌ អភិបាលរាជធានី ត្រូវរៀបចំកិច្ចប្រជុំគណៈអភិបាលរបស់ខ្លួន ដោយត្រូវមានការចូលរួមពីអភិបាលខណ្ឌសាមី ប្រធានការិយាល័យអប់រំ យុវជន និងកីឡាខណ្ឌ និងប្រធានគណៈកម្មការវាយតម្លៃ ដើម្បីពិនិត្យ ពិភាក្សា និងសម្រេចលើសំណើតែងតាំង នាយករង ដោយដីការបស់អភិបាលរាជធានី។

**ប្រការ៥ .-**

ក្នុងករណីនាយករងនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ មានកំហុស និងការផ្តាំឆ្គងក្នុងវិជ្ជាជីវៈ ក្នុងពេលបំពេញមុខងារ និងផ្អែកលើយោបល់របស់ក្រុមប្រឹក្សាវិន័យ ដោយអនុលោមតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ នាយក ត្រូវលើកសំណើទៅអភិបាលក្រុង ស្រុក ខណ្ឌ តាមរយៈប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ដើម្បីផ្អាកការងារពីមុខតំណែងនាយករងដោយដីការបស់អភិបាលរាជធានី ក្រុង ស្រុក។ ការបញ្ចប់មុខតំណែង និងការតែងតាំងនាយករងថ្មី ត្រូវអនុវត្តដោយអនុលោមតាមបទប្បញ្ញត្តិនៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ៦ .-**

លក្ខខណ្ឌសម្រាប់ការតែងតាំងនាយករង យន្តការ នៃការវាយតម្លៃបេក្ខជន និងនីតិវិធី នៃការជ្រើសរើស និងការតែងតាំង ត្រូវអនុវត្តដោយអនុលោមតាមនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការតែងតាំង ការផ្លាស់ប្តូរ និង ការបញ្ចប់មុខតំណែងនាយករង នៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ដែលជាឧបសម្ព័ន្ធ នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ៧ .-**

ការកែសម្រួលនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែង នាយករង នៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវកំណត់ដោយ ប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួង មុខងារសាធារណៈ។

## ជំពូកទី៣
## ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**ប្រការ៨ .-**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាព នៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយករងនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សា សាធារណៈ ដោយអនុលោមតាមបទប្បញ្ញត្តិនៃប្រកាសអន្តរក្រសួងនេះ។

## ជំពូកទី៤
## ទណ្ឌកម្មខាងវិន័យ

**ប្រការ៩ .-**

ត្រូវចាត់ទុកថាបានប្រព្រឹត្តកំហុស និងការធ្វេសប្រហែស ចំពោះមន្ត្រីដែលពាក់ព័ន្ធនឹងការជ្រើសរើស ការវាយតម្លៃ ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយករង នៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ដែលមិនអនុវត្តអនុលោមតាមបទប្បញ្ញត្តិនៃប្រកាសអន្តរក្រសួង និង និយាមនីតិវិធីប្រតិបត្តិសម្រាប់ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយករង នៃគ្រឹះស្ថាន មត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ។

រាល់កំហុស និងការធ្វេសប្រហែស ត្រូវអនុវត្តទណ្ឌកម្មខាងវិន័យថ្នាក់ទី២ ដូចមានកំណត់ក្នុងច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។ ការអនុវត្តទណ្ឌកម្មខាងវិន័យនេះមិន រារាំងដល់ការចោទប្រកាន់ និងការផ្តន្ទាទោសខាងព្រហ្មទណ្ឌស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានឡើយ។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**ប្រការ១០ .-**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការតែងតាំងនាយករង នៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវមានអានុភាពអនុវត្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមក ជំនួសស្របតាមបទប្បញ្ញត្តិ នៃប្រកាសអន្តរក្រសួងនេះ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១២ .-**

អភិបាលនៃគណៈអភិបាលរាជធានី ក្រុង ស្រុក ខណ្ឌ ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ប្រធានមន្ទីរមុខងារសាធារណៈ ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ប្រធានការិយាល័យគ្រប់គ្រងធនធានមនុស្ស/ប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិក និងអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសអន្តរក្រសួងនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៦កើត ខែ អាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ២០២៥

| ឧបនាយករដ្ឋមន្ត្រី<br>រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | ឧបនាយករដ្ឋមន្ត្រី<br>រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ឧបនាយករដ្ឋមន្ត្រី<br>រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ |
|---|---|---|
| **បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** | **អភិសន្តិបណ្ឌិត ស សុខា** | **ហ៊ុន ម៉ានី** |

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃប្រកាសអន្តរក្រសួងលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០២៥ស្តីពីគោលការណ៍ និងនីតិវិធី នៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយករង នៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ។

# និយាមនីតិវិធីប្រតិបត្តិ

## សម្រាប់ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែង នាយករង នៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ

ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការដឹកនាំនិងគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយករង នៃគ្រឹះស្ថានសិក្សាត្រូវអនុវត្តតាមនិយាមនីតិវិធីប្រតិបត្តិ ដូចខាងក្រោម៖

## ១. លក្ខខណ្ឌសម្រាប់ការតែងតាំងនាយករង

ការតែងតាំងនាយករង នៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវអនុវត្តផ្អែកលើលក្ខខណ្ឌចាំបាច់ និងលក្ខខណ្ឌទូទៅ ដូចខាងក្រោម៖

### ១.១. លក្ខខណ្ឌចាំបាច់

បេក្ខជនដែលត្រូវសម្រាំងដើម្បីយកមកវាយតម្លៃ ដាច់ខាតត្រូវតែបំពេញតាមលក្ខខណ្ឌចាំបាច់ ដូចតទៅ៖

- ជាមន្ត្រីរាជការក្របខ័ណ្ឌគ្រូបង្រៀន។

### ១.២. លក្ខខណ្ឌទូទៅ

**១.២.១. បំណិន** សំដៅដល់៖

- ការប្រមូលព័ត៌មាន ការសំយោគព័ត៌មាន ការបែងចែកព័ត៌មាន
- ការដឹកនាំអង្គប្រជុំ
- ការធ្វើបទបង្ហាញក្នុងអង្គប្រជុំ
- ការផ្តល់ព័ត៌មានត្រឡប់
- ការត្រិះរិះពិចារណា
- ការធ្វើសេចក្តីសម្រេចចិត្ត
- ការចរចា
- ការប្រាស្រ័យទាក់ទង
- ការដោះស្រាយបញ្ហា
- នវានុវត្តន៍។

**១.២.២. សមត្ថភាព** សំដៅដល់៖

- ការយល់ដឹងពីគោលនយោបាយ ច្បាប់ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងលិខិតរដ្ឋបាល
- ការអភិវឌ្ឍផែនការយុទ្ធសាស្ត្រសាលារៀន
- ការអភិវឌ្ឍផែនការប្រតិបត្តិប្រចាំឆ្នាំ
- ការរៀបចំផែនការប្រើប្រាស់គ្រូបង្រៀនប្រចាំឆ្នាំ
- ការរៀបចំសេវាម៉ោងបង្រៀន និងបំណែងចែកភារកិច្ចរបស់គ្រូបង្រៀន
- ការធ្វើអធិការកិច្ចផ្ទៃក្នុងសាលារៀន
- ការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុសាលារៀន
- ភាសាបរទេសអាចប្រើប្រាស់បានក្នុងការប្រាស្រ័យទាក់ទង
- ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា ទូរគមនាគមន៍ និងឌីជីថលកម្រិតមធ្យម
- ការបូកសរុបលទ្ធផលការងារ ការសរសេររបាយការណ៍ និងកំណត់ហេតុផ្សេងៗ។

**១.២.៣. បុគ្គលិកលក្ខណៈ និងលក្ខណសម្បត្តិផ្សេងៗទៀត** សំដៅដល់៖

- ភាពម៉ឺងម៉ាត់ ការប្តេជ្ញាចិត្តខ្ពស់ក្នុងការងារ និងស្មារតីទទួលខុសត្រូវក្នុងការងារ
- ការឧស្សាហ៍ព្យាយាម និងតស៊ូក្នុងការងារ
- ភាពស្មោះត្រង់ និងមានគោលជំហរច្បាស់លាស់

- ភាពយុត្តិធម៌ក្នុងការងារគ្រប់គ្រង និងការទទួលស្គាល់ការពិត
- ការទទួលខុសត្រូវខ្ពស់ក្នុងការងារ និងការផ្ដល់ឱកាសដល់សហការី
- មនសិការវិជ្ជាជីវៈខ្ពស់ និងរក្សាការសម្ងាត់វិជ្ជាជីវៈ
- មានសាមគ្គីល្អ ការធ្វើការងារជាក្រុម និងគោរពឱ្យតម្លៃអ្នកដទៃ និងសហការី
- ស្វ័យកែលម្អនូវចំណុចខ្វះខាតជាប្រចាំ សីលធម៌រស់នៅល្អ និងសុខភាពល្អ
- ភាពប៉ិនប្រសប់ក្នុងការអនុវត្តការងារ និងអភិវឌ្ឍន៍សមត្ថភាពជាប្រចាំ
- ការគាំទ្រពីសហការី ការគាំទ្រពីសហគមន៍ ដោយផ្សារភ្ជាប់សាលារៀន និងសហគមន៍។

**១.២.៤. លទ្ធផលនៃការបង្រៀន និងការគ្រប់គ្រង** សំដៅដល់៖

- លទ្ធផលនៃការបង្រៀន/ការងារគ្រប់គ្រង
- ការឆ្លងវគ្គសិក្សា/បំប៉ន(ក្នុង ឬក្រៅប្រទេស) ដើម្បីពង្រឹងសមត្ថភាពជំនាញ។

លក្ខខណ្ឌចាំបាច់ និងលក្ខខណ្ឌទូទៅ នៃការតែងតាំងនាយករង នៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវវាយតម្លៃ និងដាក់ពិន្ទុតាមតារាងវាយតម្លៃ ដូចមានកំណត់ក្នុងចំណុច ៣.៤ នៃនិយាមនេះ។

## ២. យន្តការនៃការវាយតម្លៃបេក្ខជន

ក្នុងករណីមុខតំណែងនាយករង នៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈនៅទំនេរដោយមូលហេតុផ្សេងៗ ឬនាយករងដែលត្រូវចូលនិវត្តន៍ នាយក ត្រូវបង្កើតគណៈកម្មការវាយតម្លៃ ដើម្បីជ្រើសរើសនាយករង ដែលមានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - នាយក | ប្រធាន |
| - នាយករងទាំងអស់ | អនុប្រធាន |
| - មេឃុំ/ចៅសង្កាត់ | សមាជិក |
| - ប្រធាន អនុប្រធានក្រុមបច្ចេកទេសទាំងអស់ | សមាជិក |
| - មន្ត្រីទទួលបន្ទុកបុគ្គលិក ឬលេខាធិការ ចំនួន ០១ រូប | សមាជិក។ |

សមាសភាពនៃគណៈកម្មការវាយតម្លៃ ដែលបានឈរឈ្មោះជាបេក្ខជន ត្រូវបានដកចេញពីសមាជិកគណៈកម្មការវាយតម្លៃ ។

សមាសភាពជាក់ស្ដែងនៃគណៈកម្មការវាយតម្លៃ កំណត់ដោយលិខិតបង្គាប់ការរបស់នាយកគ្រឹះស្ថានសិក្សាសាមី។

ផ្អែកលើលទ្ធផលនៃការវាយតម្លៃ ប្រធានគណៈកម្មការវាយតម្លៃ លើកសំណើទៅអភិបាលក្រុង ស្រុក ខណ្ឌ តាមរយៈប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ដើម្បីរៀបចំនីតិវិធី នៃការជ្រើសរើសជូនអភិបាលក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេលយ៉ាងយូរ ៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ។

គណៈកម្មការវាយតម្លៃមានភារកិច្ច ដូចតទៅ៖

- ផ្សព្វផ្សាយស្ដីពីការជ្រើសរើសនាយករង
- ពិគ្រោះយោបល់ជាមួយបុគ្គលិកអប់រំនៃគ្រឹះស្ថានសិក្សាសាមី

- រៀបចំការទទួលពាក្យស្នើសុំឈរឈ្មោះជាបេក្ខជន និងរៀបចំសម្រាំងបញ្ជីឈ្មោះបេក្ខជនដែលបានបំពេញលក្ខខណ្ឌចាំបាច់សម្រាប់ការវាយតម្លៃ
- រៀបចំកិច្ចដំណើរការនៃការវាយតម្លៃ និងដាក់ពិន្ទុបេក្ខជនដោយផ្អែកលើលក្ខណៈសម្បត្តិស័ក្តិសមដែលបានកំណត់ក្នុងនិយាមនេះ ដោយត្រូវធ្វើឡើងជាសម្ងាត់
- បូកសរុបលទ្ធផលនៃការវាយតម្លៃ រៀបចំកំណត់ហេតុ របាយការណ៍វាយតម្លៃ និងដាក់ពិន្ទុ
- លើកសំណើសុំតែងតាំងនាយករងទៅអភិបាលក្រុង ស្រុក ខណ្ឌ ដោយភ្ជាប់មកជាមួយនូវបញ្ជីរាយនាមមន្ត្រីស្នើសុំតែងតាំង ប្រវត្តិរូបសង្ខេបរបស់សាមីខ្លួន និងឯកសារពាក់ព័ន្ធដូចជា វិញ្ញាបនបត្រសញ្ញាបត្រជំនាញ លិខិតឯកត្តភូតពាក់ព័ន្ធនឹងមុខតំណែង ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ចុងក្រោយ
- បំពេញភារកិច្ចផ្សេងទៀតស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ៣. នីតិវិធីនៃការតែងតាំងនាយករង

ក្នុងករណីគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ មាននាយករងដែលត្រូវចូលនិវត្តន៍ នាយកត្រូវបង្កើតគណៈកម្មការវាយតម្លៃ ដើម្បីជ្រើសរើសបេក្ខភាពនាយករងជំនួស និងលើកសំណើទៅអភិបាលក្រុង ស្រុក ខណ្ឌ តាមរយៈប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ដើម្បីប្រជុំពិនិត្យ ពិភាក្សា និងសម្រេចតែងតាំងនាយករងថ្មីឱ្យបានរួចរាល់ក្នុងរយៈពេលយ៉ាងតិច ៣(បី)ខែ មុនដល់កាលកំណត់ចូលនិវត្តន៍។

ចំពោះគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ដែលមានមុខតំណែងនាយករងនៅទំនេរដោយមូលហេតុផ្សេងៗ នាយក ត្រូវបង្កើតគណៈកម្មការវាយតម្លៃ ដើម្បីជ្រើសរើសបេក្ខភាពនាយករងថ្មីជំនួស និងលើកសំណើទៅអភិបាលក្រុង ស្រុក ខណ្ឌ តាមរយៈប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ដើម្បីប្រជុំពិនិត្យ ពិភាក្សា និងសម្រេចតែងតាំងនាយករងថ្មីឱ្យបានរួចរាល់យ៉ាងយូររយៈពេល ៣(បី)ខែ។

នីតិវិធី នៃការតែងតាំងនាយករង នៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវអនុវត្តតាមជំហាន ដូចខាងក្រោម៖

### ៣.១. ជំហានទី១៖ ការពិនិត្យលើតម្រូវការជ្រើសរើសនាយករង

គណៈកម្មការវាយតម្លៃ ត្រូវប្រជុំពិនិត្យ និងវាយតម្លៃអំពីតម្រូវការជ្រើសរើសនាយករង ដើម្បីរៀបចំផ្សព្វផ្សាយ។

### ៣.២. ជំហានទី២៖ ការផ្សព្វផ្សាយព័ត៌មានអំពីការជ្រើសរើសនាយករង

ដោយផ្អែកលើតម្រូវការជ្រើសរើសនាយករង គណៈកម្មការវាយតម្លៃ ត្រូវផ្សព្វផ្សាយព័ត៌មានអំពីការជ្រើសរើសនាយករងដល់ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំទាំងអស់ក្នុងគ្រឹះស្ថានសិក្សារបស់ខ្លួនឱ្យបានទូលំទូលាយ និងជាសាធារណៈសម្រាប់រយៈពេលយ៉ាងតិច ៣០(សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការ។ ក្នុងករណីប្រញាប់ ការផ្សព្វផ្សាយត្រូវមានរយៈពេលយ៉ាងតិច ១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ។

គណៈកម្មការវាយតម្លៃ អាចប្រើប្រាស់គំរូពាក្យស្នើសុំឈរឈ្មោះជាបេក្ខជនសម្រាប់ការតែងតាំងនាយករង តាម**តារាងគំរូទី១៖** គំរូពាក្យស្នើសុំឈរឈ្មោះជាបេក្ខជនសម្រាប់ការតែងតាំងនាយករង ដូចមានភ្ជាប់ជាមួយ។

**៣.៣. ជំហានទី៣៖ ការទទួលពាក្យស្នើសុំ និងការសម្រាំងបញ្ជីឈ្មោះបេក្ខជន**

គណៈកម្មការវាយតម្លៃ ត្រូវចាត់តាំងឱ្យមានការទទួលពាក្យស្នើសុំឈរឈ្មោះជាបេក្ខជនសម្រាប់ការជ្រើសរើសនិងតែងតាំងនាយករង។ បេក្ខជនត្រូវបំពេញពាក្យស្នើសុំ និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនានា ដូចមានកំណត់ក្នុងគំរូពាក្យស្នើសុំ។

បន្ទាប់ពីផុតកំណត់នៃរយៈពេលផ្សព្វផ្សាយ គណៈកម្មការវាយតម្លៃ ត្រូវប្រជុំបូកសរុប និងសម្រាំងបញ្ជីឈ្មោះបេក្ខជនដែលមានគុណវុឌ្ឍិឆ្លើយតបនឹងលក្ខខណ្ឌចាំបាច់ និងលក្ខខណ្ឌទូទៅ ដូចមានកំណត់ក្នុង**ចំណុចទី១** នៃនិយាមនេះ ដើម្បីយកមកវាយតម្លៃ និងដាក់ពិន្ទុឱ្យបានរួចរាល់ក្នុងរយៈពេលយ៉ាងយូរ ៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ។

ក្នុងការសម្រាំងបញ្ជីឈ្មោះបេក្ខជននេះ បើពិនិត្យឃើញថាពុំមានបេក្ខជនដែលកំពុងបម្រើការងារនៅក្នុងគ្រឹះស្ថានសិក្សារបស់ខ្លួនចាប់ពី ២(ពីរ)រូប ឡើងទៅដែលឆ្លើយតបទៅនឹងលក្ខខណ្ឌចាំបាច់ និងលក្ខខណ្ឌទូទៅ ដូចបានកំណត់ក្នុងនិយាមនេះ គណៈកម្មការវាយតម្លៃ ត្រូវស្នើសុំយោបល់ទៅអភិបាលក្រុង ស្រុក ខណ្ឌសាមី តាមរយៈប្រធានការិយាល័យអប់រំ យុវជន និងកីឡា ដើម្បីស្នើសុំជ្រើសរើសបេក្ខជនដែលមានលក្ខណៈសម្បត្តិស័ក្តិសមសម្រាប់ការតែងតាំងជានាយករង ពីសាលាបឋមសិក្សា ឬមត្តេយ្យសិក្សាផ្សេងទៀតដែលស្ថិតក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌសាមី ដើម្បីយកមកសម្រាំង និងពិនិត្យវាយតម្លៃ។

បេក្ខជនដែលត្រូវបានសម្រាំងមានចំនួនយ៉ាងតិច ២(ពីរ)រូប តាមគោលការណ៍កំណត់ ដូចខាងក្រោម៖

- ក្នុងករណីបេក្ខជនដែលបានសម្រាំងមានបេក្ខភាពមកពីលេខាធិការ ប្រធានក្រុមបច្ចេកទេស ចំនួនចាប់ពី ២(ពីរ)រូបឡើងទៅ គណៈកម្មការវាយតម្លៃត្រូវសម្រេចយកតែបេក្ខជនទាំងនោះប៉ុណ្ណោះ ដើម្បីយកមកធ្វើការវាយតម្លៃ និងដាក់ពិន្ទុ
- ក្នុងករណីបេក្ខជនដែលបានសម្រាំងនេះ មានបេក្ខភាពមកពីលេខាធិការ ប្រធានក្រុមបច្ចេកទេស តិចជាង ២(ពីរ)រូប គណៈកម្មការវាយតម្លៃ ត្រូវសម្រេចយកបេក្ខភាពបន្ថែមពីអនុប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន ដើម្បីយកមកធ្វើការវាយតម្លៃ និងដាក់ពិន្ទុ សម្រាំងយកបេក្ខជនឱ្យបានយ៉ាងតិច ២(ពីរ)រូប។

**៣.៤. ជំហានទី៤៖ ការវាយតម្លៃ និងការដាក់ពិន្ទុ**

គណៈកម្មការវាយតម្លៃ ត្រូវរៀបចំកិច្ចប្រជុំដើម្បីវាយតម្លៃ និងដាក់ពិន្ទុដល់បេក្ខជនដែលមានឈ្មោះក្នុងបញ្ជីឈ្មោះសម្រាំងបេក្ខជន ដោយប្រើប្រាស់តារាងវាយតម្លៃ ដែលបានកំណត់ក្នុងនិយាមនេះ។

សមាជិកម្នាក់ៗនៃគណៈកម្មការវាយតម្លៃ មានសិទ្ធិវាយតម្លៃ និងដាក់ពិន្ទុដល់បេក្ខជនគ្រប់រូប។

សមាជិកគណៈកម្មការវាយតម្លៃ ដែលយល់ថាខ្លួនមានទំនាស់ផលប្រយោជន៍ជាមួយបេក្ខជនត្រូវស្នើសុំដកខ្លួនចេញពីគណៈកម្មការវាយតម្លៃ។

ក្នុងកិច្ចប្រជុំវាយតម្លៃ និងដាក់ពិន្ទុនេះ គណៈកម្មការវាយតម្លៃ អាចអញ្ជើញតំណាងគណៈកម្មការគ្រប់គ្រងសាលារៀន ឬអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមសង្កេតការណ៍។

ការវាយតម្លៃ និងដាក់ពិន្ទុដល់បេក្ខជន ត្រូវអនុវត្តតាមរយៈការពិនិត្យប្រវត្តិការងារ ព័ត៌មានផ្លូវការ ការសាកសួរ ការសម្ភាសន៍ ឬវិធីសាស្ត្រផ្សេងៗដែលចាំបាច់ ដោយផ្តល់ពិន្ទុផ្អែកតាមការកំណត់ដូចមានកំណត់ក្នុង**តារាងគំរូទី២៖** តារាងវាយតម្លៃ និងដាក់ពិន្ទុបេក្ខជន ដូចមានភ្ជាប់ជាមួយ។

ប្រធានគណៈកម្មការវាយតម្លៃ ត្រូវប្រមូល វេចខ្ចប់ និងបូកសរុបលទ្ធផលនៃការវាយតម្លៃ និងដាក់ពិន្ទុរបស់គណៈកម្មការវាយតម្លៃ ដោយធានានូវសុវត្ថិភាព និងការសម្ងាត់ រួចលើកសំណើជូនអភិបាលក្រុង ស្រុក ខណ្ឌ។

**៣.៥. ជំហានទី៥៖ ការពិនិត្យ និងលើកសំណើតែងតាំង**

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកិច្ចប្រជុំគណៈអភិបាលរបស់ខ្លួន ដោយត្រូវមានការចូលរួមពីប្រធានគណៈកម្មការវាយតម្លៃ ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ប្រធានការិយាល័យគ្រប់គ្រងធនធានមនុស្ស/ប្រធានការិយាល័យរដ្ឋបាលនិងបុគ្គលិក ដើម្បីពិនិត្យ និងសម្រេចលើលទ្ធផល នៃការវាយតម្លៃ និងដាក់ពិន្ទុរបស់គណៈកម្មការវាយតម្លៃ ក្នុងរយៈពេលយ៉ាងយូរ ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសំណើ។

ក្នុងការពិនិត្យសម្រេចនេះ អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវធានាឱ្យមានការពិភាក្សា និងការពិគ្រោះយោបល់គ្នាដោយផ្អែកលើពិន្ទុ នៃការវាយតម្លៃ ដើម្បីជ្រើសរើសយកបេក្ខជន ១(មួយ)រូប ដែលមានលក្ខណៈសម្បត្តិស័ក្តិសមជាងគេសម្រាប់ស្នើសុំតែងតាំងជានាយករង។

**៣.៦. ជំហានទី៦៖ ការតែងតាំងនាយករង**

ផ្អែកលើលទ្ធផលនៃកិច្ចប្រជុំឯកភាពរបស់គណៈអភិបាល អភិបាលក្រុង ស្រុក ត្រូវចេញដីកាតែងតាំងនាយករង នៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ។ ដោយឡែក រាជធានីភ្នំពេញ អភិបាលខណ្ឌ ត្រូវលើកសំណើទៅអភិបាលរាជធានីភ្នំពេញ ដើម្បីចេញដីកាតែងតាំងនាយករង។ បន្ទាប់ពីទទួលបានសំណើពីអភិបាលខណ្ឌ អភិបាលរាជធានី ត្រូវរៀបចំកិច្ចប្រជុំគណៈអភិបាលរបស់ខ្លួន ដោយត្រូវមានការចូលរួមពីអភិបាលខណ្ឌសាមី ប្រធានការិយាល័យអប់រំ យុវជន និងកីឡាខណ្ឌ និងប្រធានគណៈកម្មការវាយតម្លៃ ដើម្បីពិនិត្យ ពិភាក្សា និងសម្រេចលើសំណើតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងនាយករង ដោយដីការបស់អភិបាលរាជធានី។

ការចេញដីកាតែងតាំងនេះ ត្រូវធ្វើឡើងយ៉ាងយូរ ១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ។

ក្នុងករណីមិនឯកភាពលើសំណើរបស់គណៈកម្មការវាយតម្លៃ ឬសំណើរបស់អភិបាលខណ្ឌ គណៈកម្មការវាយតម្លៃ ត្រូវរៀបចំនីតិវិធីជ្រើសរើសបេក្ខជនថ្មីស្របតាមបែបបទ និងនីតិវិធីដែលមានកំណត់ក្នុងនិយាមនេះ។

**៣.៧. ជំហានទី៧៖ ការប្រកាសចូលកាន់មុខតំណែង**

នាយកត្រូវរៀបចំការប្រកាសចូលកាន់តំណែងនាយករងថ្មី បន្ទាប់ពីដីកាតែងតាំងនាយករងចូលជាធរមានក្នុងរយៈពេលយ៉ាងយូរ ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការ។ នាយករងថ្មី ត្រូវចូលបំពេញមុខងារជាផ្លូវការបន្ទាប់ពីការប្រកាសចូលកាន់មុខតំណែង។

តារាងគំរូទី១៖ គំរូពាក្យ ស្នើសុំឈរឈ្មោះជាបេក្ខជនសម្រាប់ការតែងតាំងនាយករង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ......................កើតនៅថ្ងៃទី.......ខែ...........ឆ្នាំ..................មានក្របខ័ណ្ឌគ្រូបង្រៀនកម្រិត.......(.......) បច្ចុប្បន្នជា.....................................................................។

**សូមគោរពជូន**
**លោក/លោកស្រីប្រធានគណៈកម្មការវាយតម្លៃ**

**កម្មវត្ថុ** ៖ សំណើសុំឈរឈ្មោះជាបេក្ខជន ដើម្បីវាយតម្លៃស្នើសុំតែងតាំងជានាយករង នៃសាលា......................។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាបជូន **លោក/លោកស្រីប្រធាន** មេត្តាជ្រាបថា ខ្ញុំបាទ/នាងខ្ញុំមានបំណងឈរឈ្មោះជាបេក្ខជន ដើម្បីវាយតម្លៃស្នើសុំតែងតាំងជានាយករង។

សូមភ្ជាប់មកជាមួយនូវ៖

- ប្រវត្តិរូបសង្ខេប ចំនួន ១(មួយ)ច្បាប់
- សញ្ញាបត្រ និងឯកសារពាក់ព័ន្ធ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **លោក/លោកស្រីប្រធាន** មេត្តាពិនិត្យលទ្ធភាពអនុញ្ញាតឱ្យរូបខ្ញុំបាទ/នាងខ្ញុំបានឈរឈ្មោះ ដោយសេចក្តីអនុគ្រោះ។

សូម **លោក/លោកស្រីប្រធាន** ទទួលនូវការគោរពដ៏ស្មោះពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ ខែ ឆ្នាំ.......... ព.ស.២៥......
....................ថ្ងៃទី ខែ ឆ្នាំ២០.....
**ហត្ថលេខា**

(ឈ្មោះសាមីជន)

**តារាងគំរូទី២៖ តារាងវាយតម្លៃ និងដាក់ពិន្ទុបេក្ខជន**

| ១- កម្រិតបណ្តុះបណ្តាល៖ សញ្ញាបត្រ និងចំណេះដឹងឯកទេស | ពិន្ទុត្រូវផ្តល់តាមផ្នែក (ពិន្ទុសរុប.../២០) |
|---|---|
| សញ្ញាបត្របណ្ឌិត | ៥ |
| សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ | ៣ |
| សញ្ញាបត្របរិញ្ញាបត្រ | ៣ |
| បរិញ្ញាបត្ររង ឬសញ្ញាបត្រសមមូល | ៣ |
| មធ្យមសិក្សាទុតិយភូមិបូក២ ឬសញ្ញាបត្រសមមូល | ៣ |
| ចំណេះដឹងឯកទេស៖ វិញ្ញាបនបត្រវិជ្ជាជីវៈនាយកសាលារៀន/គ្រូបង្រៀនល្អ | ៣ |
| **២- បំណិន៖** | (ពិន្ទុសរុប.../១០) |
| ២.១) ការប្រមូលព័ត៌មាន ការសំយោគព័ត៌មាន ការបែងចែកព័ត៌មាន | ១ |
| ២.២) ការដឹកនាំអង្គប្រជុំ | ១ |
| ២.៣) ការធ្វើបទបង្ហាញក្នុងអង្គប្រជុំ | ១ |
| ២.៤) ការផ្តល់ព័ត៌មានត្រឡប់ | ១ |
| ២.៥) ការត្រិះរិះពិចារណា | ១ |
| ២.៦) ការធ្វើសេចក្តីសម្រេចចិត្ត | ១ |
| ២.៧) ការចរចា | ១ |
| ២.៨) ការប្រាស្រ័យទាក់ទង | ១ |
| ២.៩) ការដោះស្រាយបញ្ហា | ១ |
| ២.១០) នវានុវត្តន៍/ការបង្កើតថ្មី | ១ |
| **៣- សមត្ថភាព (៣០ ពិន្ទុ)៖** | (ពិន្ទុសរុប.../៣០) |
| ៣.១) ការយល់ដឹងពីគោលនយោបាយ ច្បាប់ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងលិខិតរដ្ឋបាល ពាក់ព័ន្ធវិស័យអប់រំ យុវជន និងកីឡា | ៣ |
| ៣.២) ការអភិវឌ្ឍផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន | ៤ |
| ៣.៣) ការអភិវឌ្ឍផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន | ២ |
| ៣.៤) ការរៀបចំផែនការប្រើប្រាស់គ្រូបង្រៀនប្រចាំឆ្នាំ ផ្អែកតាមនិយាមប្រើប្រាស់បុគ្គលិក | ៣ |
| ៣.៥) ការរៀបចំសេវាម៉ោងបង្រៀន និងបំណែងចែកភារកិច្ចរបស់គ្រូបង្រៀន | ២ |
| ៣.៦) ការធ្វើអធិការកិច្ចផ្ទៃក្នុងសាលារៀន | ១ |
| ៣.៧) ការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុសាលារៀន | ៣ |
| ៣.៨) ភាសាបរទេស អាចប្រើប្រាស់បានក្នុងការប្រាស្រ័យទាក់ទង | ៥ |
| ៣.៩) ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា ទូរគមនាគមន៍ និងឌីជីថលក្នុងការបំពេញការងារប្រចាំថ្ងៃ ( Ms. Word, Ms. Excel, Ms. PowerPoint, Telegram...) កម្រិតមធ្យម | ៥ |
| ៣.១០) បូកសរុបលទ្ធផលការងារ សរសេររបាយការណ៍ និងកំណត់ហេតុផ្សេងៗ | ២ |
| **៤- បុគ្គលិកលក្ខណៈ និងលក្ខណសម្បត្តិផ្សេងៗទៀត៖** | (ពិន្ទុសរុប.../២០) |

| | |
|---|---|
| ៤.១) ភាពម៉ឺងម៉ាត់ ប្ដេជ្ញាចិត្តខ្ពស់ និងស្មារតីទទួលខុសត្រូវក្នុងការងារ | ២ |
| ៤.២) ការឧស្សាហ៍ព្យាយាម និងតស៊ូក្នុងការងារ | ២ |
| ៤.៣) ភាពស្មោះត្រង់ និងមានគោលជំហរច្បាស់លាស់ | ២ |
| ៤.៤) ភាពយុត្តិធម៌ក្នុងការងារគ្រប់គ្រង និងការទទួលស្គាល់ការពិត | ២ |
| ៤.៥) ការទទួលខុសត្រូវខ្ពស់ក្នុងការងារ និងផ្ដល់ឱកាសដល់សហការី | ២ |
| ៤.៦) មនសិការវិជ្ជាជីវៈខ្ពស់ និងរក្សាការសម្ងាត់វិជ្ជាជីវៈ | ២ |
| ៤.៧) មានសាមគ្គីល្អ ការធ្វើការងារជាក្រុម និងគោរពឱ្យតម្លៃអ្នកដទៃ និងសហការី | ២ |
| ៤.៨) ស្វ័យកែលម្អនូវចំណុចខ្វះខាតជាប្រចាំ សីលធម៌រស់នៅល្អ និងសុខភាពល្អ | ១ |
| ៤.៩) ភាពប៉ិនប្រសប់ក្នុងការអនុវត្តការងារ និងអភិវឌ្ឍន៍សមត្ថភាពជាប្រចាំ | ២ |
| ៤.១០) ការគាំទ្រពីសហការី និងការគាំទ្រពីសហគមន៍ | ១ |
| ៤.១១) ការចូលរួមអនុវត្តការងារសង្គម(មានការបញ្ជាក់ពីក្រុមប្រឹក្សាឃុំសង្កាត់ ឬគណៈអភិបាលក្រុង ស្រុក ខណ្ឌ) | ២ |
| **៥- លទ្ធផល(បង្រៀន/គ្រប់គ្រង)/ចូលរួមវគ្គសិក្សា (១០ ពិន្ទុ)៖** | **(ពិន្ទុសរុប.../១០)** |
| ៥.១) លទ្ធផលនៃការបង្រៀន/ការងារគ្រប់គ្រង | ៧ |
| ៥.២) ការឆ្លងវគ្គសិក្សា/បំប៉ន(ក្នុង ឬក្រៅប្រទេស) ដើម្បីពង្រឹងសមត្ថភាពជំនាញ | ៣ |
| **៦- បទពិសោធការងារ** | **(ពិន្ទុសរុប.../១០)** |
| ៦.១) មានបទពិសោធជាលេខាធិការ ប្រធានក្រុមបច្ចេកទេស (១០ ពិន្ទុ)៖ | |
| - ក្រោម ១ឆ្នាំ | ២ |
| - ចាប់ពី ១ឆ្នាំ ដល់ ៤ឆ្នាំ | ៤ |
| - ចាប់ពី ៥ឆ្នាំ ដល់ ១៥ឆ្នាំ | ៦ |
| - ចាប់ពី ១៦ឆ្នាំ ដល់ ២០ឆ្នាំ | ៨ |
| - លើសពី ២០ឆ្នាំ | ១០ |
| ៦.២) មានបទពិសោធជាអនុប្រធានក្រុមបច្ចេកទេស ឬគ្រូបង្រៀន (ពិន្ទុសរុប ៨ពិន្ទុ)៖ | |
| - ចាប់ពី ១ឆ្នាំ ដល់ ៤ឆ្នាំ | ២ |
| - ចាប់ពី ៥ឆ្នាំ ដល់ ១៥ឆ្នាំ | ៤ |
| - ចាប់ពី ១៦ឆ្នាំ ដល់ ២០ឆ្នាំ | ៦ |
| - លើសពី ២០ឆ្នាំ | ៨ |

| | | |
|---|---|---|
| **ឈ្មោះសាមីជន៖**<br>**ឈ្មោះអ្នកវាយតម្លៃ៖** | ..........................................................<br>.......................................................... | **ពិន្ទុសរុប (១០០)** |

**សម្គាល់៖**

- ពិន្ទុសរុប ១០០ ល្អណាស់
- ពិន្ទុសរុបចាប់ពី ៩០ ដល់ ៩៩ ល្អ
- ពិន្ទុសរុបចាប់ពី ៧០ ដល់ ៨៩ ល្អបង្គួរ
- ពិន្ទុសរុបតូចជាង ៧០ មធ្យម។
- បេក្ខជនជានារី ត្រូវបានផ្ដល់អាទិភាពសម្រាប់ការតែងតាំងជានាយករង នៃគ្រឹះស្ថានបឋមសិក្សាសាធារណៈ និងមត្តេយ្យសិក្សាសាធារណៈ។